# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៦ អនក្រ.បក

## អនុក្រឹត្យ
ស្តីពី
ការធ្វើអនុប្បយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/១៤៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងលិខិតលេខ ៣១៦/២០ លស ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

## សម្រេច

**មាត្រា១.**_

ត្រូវបានធ្វើអនុប្បយោគផ្ទៃដីមួយកន្លែង មានចំនួន៣(បី)ល្វែង ទំហំ២៤០(ពីររយសែសិប) ម៉ែត្រការ៉េ និងអគារចំនួន៣(បី)ល្វែង ($E_0$+$E_1$) មានទំហំ៤០០(បួនរយ)ម៉ែត្រការ៉េ មានទីតាំងនៅប្លុកអក្សរ(U) ស្ថិតនៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីប្រគល់ជូនក្រុមគ្រួសារមន្ត្រីរាជការចំនួន៣គ្រួសារ (ដូចមានក្នុងគំនូសប្លង់បង្ហាញទីតាំងភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ)។

**មាត្រា២.**_

ផ្ទៃដីដែលបានធ្វើអនុប្បយោគដូចមានកំណត់ក្នុងមាត្រា១ខាងលើនេះ ត្រូវចាត់នីតិវិធីបន្តដោយក្រសួងពាណិជ្ជកម្មដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីក្នុងការជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនក្រុមគ្រួសារមន្ត្រីរាជការ ឱ្យទទួលបានកម្មសិទ្ធិស្របច្បាប់ ស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង-ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គំនូសបង្ហាញទីតាំងអចលនវត្ថុ**

របស់មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ ដែលត្រូវកាត់ចេញអចលនវត្ថុរួមមានដី ០២កន្លែង ចំនួន ០៣ល្វែងមានទំហំ ២៤០ម២ និងអគារ ០៣ល្វែង ($E_0$+$E_1$) មានទំហំ ៤០០ម២ ប្រគល់ជូនក្រុមគ្រួសារមន្ត្រីរាជការ ចំនួន ០៣គ្រួសារ នៅប៉ុកអក្សរអ៊ុយ ស្ថិតនៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

**យោង :** - លិខិតស្នើសុំលេខ: ៥៣៩ ពណខ.បជ ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ ។




**កំណត់សំគាល់**

- ក្បាលដី និង អគារ ស្នើសុំកាត់ចេញពីបញ្ជីសារពើភណ្ឌទ្រព្យរដ្ឋ ចំនួន ០៣ល្វែង
  - \+ ដី ០៣ល្វែង ទំហំ :12m x 20m = 240m²
  - \+ អគារចំនួន ០៣ល្វែង ០១ជាន់ ($E_0$ + $E_1$) ទំហំ(4m x 20m) x 5 =400m²

(ក) ឈ្មោះ ទេស សឿន កាន់កាប់ដី ១ល្វែង ទំហំ = 4m x 20m = 80m²
អគារចំនួន ០១ល្វែង ($E_0$) ទំហំ (4m x 20m) =80m²

(ខ) ឈ្មោះ ឆើត សារ៉ាយ កាន់កាប់ដី ១ល្វែង ទំហំ (4m x 20m) = 80m²
អគារចំនួន ០១ល្វែង ($E_0$ + $E_1$) ទំហំ (4m x 20m)x2 =160m²

(គ) ឈ្មោះ ជិប ហុង កាន់កាប់ដី ១ល្វែង ទំហំ = 4m x 20m = 80m²
អគារចំនួន ០១ល្វែង ($E_0$ + $E_1$) ទំហំ (4m x 20m)x2 =160m²

ផ្លូវ

ថ្ងៃ អង្គារ ១២រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
បន្ទាយមានជ័យ .ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២០
**អ្នកចង្អុលបង្ហាញទីតាំងអចលនវត្ថុ**
**តំណាងដោយមន្ទីរពាណិជ្ជកម្មខេត្ត**

**ប៊ុក ឡាយឌី**